**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

ថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

លេខ ០៦៨/២៦ ក. ស. ភ.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបុគ្គលិក

កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជនទាំងអស់ឲ្យបានជ្រាបថា ក. ស. ភ. ត្រូវការជ្រើសរើសបុគ្គលិកចំនួន **៥៦**រូប ដើម្បីបំពេញភារកិច្ចទទួលខុសត្រូវ និងបំពេញលក្ខខណ្ឌជ្រើសរើស (មានលម្អិតក្នុងឯកសារភ្ជាប់ជូន) ដូចខាងក្រោម៖

I. <u>នាយកដ្ឋានរដ្ឋបាល</u>

១. អនុប្រធានការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ចំនួន ១រូប
២. បុគ្គលិកការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា (Network Engineer) ចំនួន ១រូប

II. <u>នាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ</u>

១. អនុប្រធានការិយាល័យហិរញ្ញវត្ថុ/ទីផ្សារមូលបត្រ ទទួលបន្ទុកផ្សារមូលបត្រ ចំនួន ១រូប
២. បុគ្គលិកផ្នែកជំនួយការបេឡានៅចំណតផែកុងតឺន័រ LM១៧ ចំនួន ១រូប
៣. បុគ្គលិកផ្នែកសិក្សាចំណូល/ចំណាយ និងវិភាគរបាយការណ៍ ចំនួន ១រូប

III. <u>នាយកដ្ឋានវិស្វកម្ម</u>

១. បុគ្គលិកផ្នែកវិស្វកម្មសំណង់ស៊ីវិល ចំនួន ១រូប
២. បុគ្គលិកផ្នែកស្ថាបត្យកម្ម ចំនួន ១រូប
៣. បុគ្គលិកផ្នែកអនុវត្តគម្រោង ចំនួន ១រូប

IV. <u>នាយកដ្ឋានគ្រប់គ្រងគ្រឿងចក្រ</u>

១. បុគ្គលិកបញ្ជារថស្ទូច Rubber Tyred Gantry Crane (RTG) ចំនួន ៣រូប
២. បុគ្គលិកបញ្ជាដងយោង Fixed Cargo Crane (FCC) ចំនួន ៤រូប
៣. បុគ្គលិកបញ្ជារថស្ទូច Empty Container Stacker ចំនួន ៤រូប
៤. បុគ្គលិកបញ្ជារថស្ទូច ៥០តោន និង ៧០តោន ចំនួន ២រូប
៥. បុគ្គលិកបើកបររថយន្ត Terminal Tractor ចំនួន ១៧រូប
៦. បុគ្គលិកផ្នែកមេកានិច ចំនួន ៣រូប
៧. បុគ្គលិកផ្នែកអេឡិចត្រូនិច ចំនួន ២រូប
៨. បុគ្គលិកផ្នែកផ្សារតោន ចំនួន ១រូប

V. <u>នាយកដ្ឋានសេវាកម្មនាវាចរណ៍</u>

១. បុគ្គលិកផ្នែកបរិស្ថាន នៅចំណតផែកុងតឺន័រ LM១៧ ចំនួន ២រូប

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តីវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh

VI. <u>នាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក</u>

១. បុគ្គលិកផ្នែកកត់ត្រាទំនិញ នៅចំណតផែទន្លេបិទ UM២ ចំនួន ១រូប

២. បុគ្គលិកផ្នែកអនុរក្ស (ចងពួរដោះពួរនាវា) នៅចំណតផែទន្លេបិទ UM២ ចំនួន ១រូប

VII. <u>នាយកដ្ឋានផែនការ/ទីផ្សារ</u>

១. អនុប្រធានការិយាល័យតម្លៃ/ទីផ្សារ ចំនួន ១រូប

២. បុគ្គលិកការិយាល័យតម្លៃ/ទីផ្សារ ចំនួន ១រូប

៣. បុគ្គលិកផែនការគ្រឿងចក្រ ចំនួន ១រូប

៤. បុគ្គលិកផែនការហេដ្ឋារចនាសម្ព័ន្ធ ចំនួន ១រូប

៥. បុគ្គលិកផ្នែកកិច្ចការជំនួញ/ប្រព័ន្ធ TOS ចំនួន ១រូប

៦. បុគ្គលិកផ្នែកភស្តុភារកម្ម ចំនួន ១រូប

៧. បុគ្គលិកការិយាល័យស្រាវជ្រាវ/អភិវឌ្ឍន៍ថ្មី ចំនួន ១រូប

VIII. <u>នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧</u>

១. បុគ្គលិកផ្នែកវិក្កយបត្រ នៅចំណតផែកុងតឺន័រ LM១៧ ចំនួន ១រូប

បើបេក្ខជនមានចំណាប់អារម្មណ៍ សូមចូលរួមដាក់ពាក្យប្រលងប្រជែងចូលបម្រើការងារនៅក. ស. ភ. ដោយមានភ្ជាប់ជាមួយនូវប្រវត្តិរូបសង្ខេប (CV) និង Cover Letter ដោយមានបិទរូបថតថ្មីទំហំ ៤ x ៦ លិខិតបញ្ជាក់សញ្ញាបត្រ ឬការសិក្សា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ លិខិតបញ្ជាក់កំណើត និងប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ (ឯកសារថតចម្លង) មកដាក់នៅទីស្នាក់ការកណ្តាលកំពង់ផែស្វយ័តភ្នំពេញ (ចំណតផែ TS៣) ដែលមានទីតាំងស្ថិតនៅ អគារលេខ ៦៤៩ បន្ទប់១១០ តឺរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈអ៊ីម៉ែល ឬតេឡេក្រាមដូចខាងក្រោម៖

អ៊ីម៉ែល: rimsokrath@gmail.com / chitphanetedu@gmail.com

តេឡេក្រាម: Rim Sokrath (លេខទូរស័ព្ទ: ០១០ ៤៤៤ ៥៣៨)

Phanet Chit (លេខទូរស័ព្ទ: ០១០ ៤៤៤ ២៣៩)

លេខទូរស័ព្ទទំនាក់ទំនង: ០១០ ៤៤៤ ៥៣៨/០១០ ៤៤៤ ២៣៩/០៩៣ ៤៤៤ ៥១៧

**កាលបរិច្ឆេទឈប់ទទួលពាក្យ**: ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២

**បញ្ជាក់**: - បេក្ខជនដែលជាប់ក្នុងបញ្ជីសម្រាំងជ្រើសរើស (Short-listed candidates) នឹងត្រូវបានជូនដំណឹងស្តីពីការចូលរួមប្រលង ក្នុងគេហទំព័ររបស់ក. ស. ភ. (www.ppap.com.kh)

- រាល់ឯកសារដែលបានដាក់ពាក្យរួចហើយរបស់បេក្ខជន មិនអាចដកវិញបានទេ។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**ប្រធានអគ្គនាយក**

**ហ៊ី~ បាទី**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ០៨៩/២៦....ក. ស. ភ.

ថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព. ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦

# សេចក្តីលម្អិតព័ត៌មាន
## ស្តីពី
## ការជ្រើសរើសបុគ្គលិក

**កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជនទាំងអស់ឲ្យបានជ្រាបថា ក. ស. ភ. ត្រូវការជ្រើសរើសបុគ្គលិកចំនួន **៥៦**រូប ដើម្បីបំពេញភារកិច្ចទទួលខុសត្រូវ និងបំពេញលក្ខខណ្ឌជ្រើសរើសដូចខាងក្រោម៖

### I. __នាយកដ្ឋានរដ្ឋបាល__

**១. អនុប្រធានការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា (ចំនួន ១ រូប)**

**ក. __ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)__**

- ប្រឹក្សាយោបល់ដល់ប្រធានការិយាល័យក្នុងការពង្រឹងវិស័យបច្ចេកវិទ្យាសម្រាប់ ក. ស. ភ.
- ធ្វើផែនការប្រចាំឆ្នាំ
- រៀបចំផែនការសកម្មភាព (Action Plan) សម្រាប់ការិយាល័យ
- ប្រមូលទិន្នន័យ និងវិភាគការសម្រេចបានរបស់ការិយាល័យ ICT ឆ្នាំកន្លងធៀបនឹងបច្ចុប្បន្ន
- ប្រមូលទិន្នន័យ និងវិភាគការសម្រេចបានរបស់ការិយាល័យក្នុងឆ្នាំ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យជាប្រចាំខែ ដាក់ជូនប្រធានការិយាល័យ
- ធ្វើបច្ចុប្បន្នភាពកុំព្យូទ័រក្នុង ក. ស. ភ. និងឧបករណ៍ផ្សេងៗរបស់ការិយាល័យ IT។

**ខ. __លក្ខខណ្ឌជ្រើសរើស (Job Requirements)__**

- បរិញ្ញាបត្រគ្រប់គ្រងអាជីវកម្ម (អាទិភាព) ឬ បរិញ្ញាបត្រ IT
- មានជំនាញក្នុងការប្រើប្រាស់ Power BI, Microsoft Project, Tello,...
- មានចំណេះដឹងលើការប្រើប្រាស់ Microsoft Visio, Mind Map manager
- មានចំណេះដឹងលើការប្រើប្រាស់ File Maker server and client (អាទិភាព)
- ជាមនុស្សលម្អិត ឯករាជ្យក្នុងការសម្រេចចិត្ត អាចធ្វើការក្រោមសម្ពាធ
- មានបទពិសោធន៍ជាអ្នកដឹកនាំក្រុម (team leader) ឬជាអ្នកមើលការងារខុសត្រូវ (Supervisor) តាមការិយាល័យ ឬជាប្រធានការិយាល័យ IT យ៉ាងតិច ៥ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តីរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៨២៧ ៨០២ Email: ppapmpwt@online.com.kh

២. បុគ្គលិកការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា (Network Engineer) (ចំនួន ១ រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- Configure CISCO Routing and switching
- Configure on Fortiget Firewall
- មើលថែទាំ network infrastructure / network security
- Help desk support
- ត្រួតពិនិត្យឧបករណ៍ក្នុង Datacenter
- ធ្វើរបាយការណ៍ប្រចាំខែ និងពេលមានបញ្ហាកើតឡើងលើ Computer network/ security។

ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)

- បរិញ្ញាបត្រ IT
- មានជំនាញក្នុងការគ្រប់គ្រង CISCO routing and switching, Firewall,
- មានជំនាញក្នុងការរៀបចំ Network Infrastructure, Security design
- មានសញ្ញាបត្រ CCNA
- ប្រឹក្សាយោបល់ដល់ប្រធានការិយាល័យក្នុងការពង្រឹងវិស័យបច្ចេកវិទ្យាសម្រាប់ ក. ស. ភ. និង computer network/ security
- មានបទពិសោធន៍យ៉ាងតិច ៤ឆ្នាំក្នុងការគ្រប់គ្រងឧបករណ៍ CISCO/ Firewall
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

## II. នាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ

១. អនុប្រធានការិយាល័យហិរញ្ញវត្ថុ/ទីផ្សារមូលបត្រ ទទួលបន្ទុកផ្សារមូលបត្រ (ចំនួន ១ រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- តាមដានព័ត៌មានការជួញដូរភាគហ៊ុន ក. ស. ភ. ជាប្រចាំ និងរៀបចំរបាយការណ៍ភាគហ៊ុន ក. ស. ភ. ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ត្រួតពិនិត្យការរៀបចំ និងរក្សាបញ្ជីឈ្មោះភាគហ៊ុនិកជាប្រចាំ
- ចូលរួមរៀបចំព័ត៌មានភាគហ៊ុន ក. ស. ភ. ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូននិយ័តករមូលបត្រកម្ពុជា (ន. ម. ក.) ឲ្យបានទាន់ពេលវេលា
- ផ្តល់ព័ត៌មានដែលទាក់ទងនឹងភាគហ៊ុនរបស់ ក. ស. ភ. សម្រាប់បង្ហាញជូនភាគហ៊ុននិកវិនិយោគិន និងភាគីពាក់ព័ន្ធនានា ដែលមានបំណងវិនិយោគ និងស្វែងយល់ពីឱកាសវិនិយោគជាមួយ ក. ស. ភ.
- ចូលរួមផ្តល់យោបល់ក្នុងការរៀបចំយុទ្ធសាស្ត្រ ដើម្បីជំរុញទីផ្សារភាគហ៊ុនរបស់ ក. ស. ភ. ឲ្យមានភាពល្អប្រសើរ
- តាមដានអំពីការវិវត្តន៍នៃវិស័យផ្សារមូលបត្រកម្ពុជានិងវិស័យដែលពាក់ព័ន្ធនានា
- រៀបចំរបាយការណ៍ការសិក្សាអំពីការវិវត្តន៍ណាដែលអាចមានផលប៉ះពាល់ឬឱកាសរីកចម្រើនដល់ស្ថានភាពហិរញ្ញវត្ថុ ក. ស. ភ.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ខ. <u>លក្ខខណ្ឌជ្រើសរើស (Job Requirements)</u>

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រឡើងទៅ ជំនាញគណនេយ្យ ហិរញ្ញវត្ថុ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ៣ ឆ្នាំ
- មានសមត្ថភាពលើការវិភាគព័ត៌មានភាគហ៊ុនរបស់ ក. ស. ភ.
- មានសមត្ថភាពប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័របានល្អ
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អ
- មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

**២. បុគ្គលិកផ្នែកជំនួយការបេឡានៅចំណតផែកុងតឺន័រ LM១៧ (ចំនួន ១រូប)**

ក. <u>ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)</u>

- ទទួលប្រាក់កក់ពីអតិថិជន
- ត្រួតពិនិត្យប្រព័ន្ធ (Portal) E-Payment
- Payment ក្នុងប្រព័ន្ធ TOS
- ផ្ទៀងផ្ទាត់ Bank slipe ជាមួយវិក្កយបត្រ រួចវាយត្រា Paid
- ធ្វើរបាយការណ៍ចំណូលប្រចាំថ្ងៃ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ខ. <u>លក្ខខណ្ឌជ្រើសរើស (Job Requirements)</u>

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រឡើងទៅ ជំនាញគណនេយ្យ ហិរញ្ញវត្ថុ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ ឆ្នាំ
- មានសមត្ថភាពប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័របានល្អ
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អ
- មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

**៣. បុគ្គលិកផ្នែកសិក្សាចំណូល/ចំណាយ និងវិភាគរបាយការណ៍ (ចំនួន ១រូប)**

ក. <u>ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)</u>

- រៀបចំការបកស្រាយ វិភាគចំណូល/ចំណាយ និងវិភាគព័ត៌មានហិរញ្ញវត្ថុដើម្បីផ្តល់ជាអនុសាសន៍ជូនថ្នាក់ដឹកនាំពាក់ព័ន្ធនឹងស្ថានភាពហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍អំពីប្រសិទ្ធភាពនៃការប្រើប្រាស់ទុន និងទ្រព្យសកម្មរបស់ ក. ស. ភ.
- ផ្តល់ជាអនុសាសន៍ទៅលើទ្រព្យសកម្មរយៈពេលវែងដែលអស់អាយុកាល និងទិញទ្រព្យសកម្មរយៈពេលវែងថ្មីជំនួសទ្រព្យសកម្មរយៈពេលវែងដែលមិនអាចប្រើប្រាស់បាន

- រៀបចំការវិភាគព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានភាគហ៊ុនប្រចាំត្រីមាស និងប្រចាំឆ្នាំ
- វិភាគនិន្នាការទីផ្សារ និងដៃគូប្រកួតប្រជែងក្នុងគោលដៅស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយក៏ដូចជា ឱកាសរីកចម្រើន ឬផលប៉ះពាល់ណាមួយដល់ ក. ស. ភ. នាពេលអនាគត
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ខ. <u>លក្ខខណ្ឌជ្រើសរើស (Job Requirements)</u>

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រឡើងទៅ ជំនាញគណនេយ្យ ហិរញ្ញវត្ថុ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ ឆ្នាំ
- មានសមត្ថភាពលើការវិភាគចំណូល/ចំណាយ វិភាគព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានភាគហ៊ុន
- មានសមត្ថភាពប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័របានល្អ
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អ
- មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

## III. <u>**នាយកដ្ឋានវិស្វកម្ម**</u>

### ១. បុគ្គលិកផ្នែកវិស្វកម្មសំណង់ស៊ីវិល (ចំនួន ១រូប)

ក. <u>ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)</u>

- សិក្សាលម្អិតលើគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផែ
- សិក្សាលើគម្រោង ជួសជុលថែទាំ ហេដ្ឋារចនាសម្ព័ន្ធផែទាំងអស់ ដែលមានស្រាប់ និងតាមដានការអនុវត្តគម្រោង
- ចង្អុលបង្ហាញ និងណែនាំលក្ខណៈបច្ចេកទេសដល់ផ្នែកថែទាំហេដ្ឋារចនាសម្ព័ន្ធផែ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ខ. <u>លក្ខខណ្ឌជ្រើសរើស (Job Requirements)</u>

- មានបរិញ្ញាបត្រផ្នែកវិស្វកម្មសំណង់ស៊ីវិល ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារយ៉ាងតិច ១ ឆ្នាំ
- មានចំណេះដឹង និងជំនាញផ្នែកគណនាគ្រឿងបង្គុំ និងចុះត្រួតពិនិត្យការដ្ឋាន
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អលើការសរសេរ អាន ស្តាប់ និងនិយាយ
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រលើជំនាញវិស្វកម្ម Ms. Word, Excel & Power Point
- មានអាយុចន្លោះពី ២៣ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានកាយសម្បទាល្អគ្រប់គ្រាន់
- មានចរិតស្លូតបូត សុភាពរាបសារ និងរួសរាយរាក់ទាក់
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

២. បុគ្គលិកផ្នែកស្ថាបត្យកម្ម (ចំនួន ១រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- គូរប្លង់គម្រោងហេដ្ឋារចនាសម្ព័ន្ធដៃ
- សហការការងារជាមួយផ្នែកសិក្សាគម្រោង
- ចង្អុលបង្ហាញ និងណែនាំលក្ខណៈបច្ចេកទេសដល់ផ្នែកអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដៃ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)

- មានបរិញ្ញាបត្រផ្នែកស្ថាបត្យកម្ម ផ្នែកវិស្វកម្មសំណង់ស៊ីវិល ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារយ៉ាងតិច ១ ឆ្នាំ
- មានចំណេះដឹង និងជំនាញលើការគូស រចនា សិក្សាប្លង់ និងចុះត្រួតពិនិត្យការដ្ឋាន
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អលើការសរសេរ អាន ស្តាប់ និងនិយាយ
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រលើជំនាញស្ថាបត្យកម្ម Ms. Word, Excel & Power Point
- មានអាយុចន្លោះពី ២៣ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

៣. បុគ្គលិកផ្នែកអនុវត្តគម្រោង (ចំនួន ១រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- ដឹកនាំត្រួតពិនិត្យ តាមដាន និងវាយតម្លៃរាល់គម្រោងអនុវត្តហេដ្ឋារចនាសម្ព័ន្ធដៃឱ្យបានសមស្រប ទៅតាមបទដ្ឋានបច្ចេកទេស
- ដឹកនាំក្រុមការងារតាមដានគម្រោងហេដ្ឋារចនាសម្ព័ន្ធដៃនៅតាមចំណាតដៃនីមួយៗ
- សម្របសម្រួល និងដោះស្រាយបញ្ហានានាជាមួយផ្នែកពាក់ព័ន្ធ នៃគម្រោងអនុវត្តហេដ្ឋារចនាសម្ព័ន្ធដៃ ឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល
- ពិនិត្យ និងផ្ទៀងផ្ទាត់លើរបាយការណ៍ការងារនៃគម្រោងអនុវត្តហេដ្ឋារចនាសម្ព័ន្ធដៃ
- ស្រាវជ្រាវ និងរៀបចំចងក្រងនូវបទដ្ឋានបច្ចេកទេសក្នុងការវាយតម្លៃលម្អិត និងបទដ្ឋានបច្ចេក-ទេស ក្នុងការចុះត្រួតពិនិត្យការអនុវត្តគម្រោង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)

- មានបរិញ្ញាបត្រផ្នែកវិស្វកម្ម, បរិញ្ញាបត្រផ្នែកគ្រប់គ្រងគម្រោង, ឬបរិញ្ញាបត្រដែលមានតម្លៃស្មើ (សញ្ញាបត្រអនុបណ្ឌិតផ្នែកវិស្វកម្ម ឬផ្នែកគ្រប់គ្រងគម្រោង ត្រូវបានផ្តល់អាទិភាព)
- មានបទពិសោធន៍ការងារយ៉ាងតិច ៣ ឆ្នាំឡើងទៅ
- មានចំណេះដឹង និងជំនាញច្បាស់លាស់ផ្នែកវិស្វកម្ម
- មានសមត្ថភាពលើការវិភាគទិន្នន័យ និងវិភាគគម្រោងអនុវត្ត
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រផ្នែកវិស្វកម្មបានល្អ
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អ

- អាចបំពេញការងារនៅការិយាល័យ និងកន្លែងផ្សេងៗ ទៅតាមការចាត់តាំង
- អាចធ្វើការងារជាក្រុមបានល្អ និងមានទំនាក់ទំនងការងារល្អ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

## IV. នាយកដ្ឋានគ្រប់គ្រងគ្រឿងចក្រ

### ១. បុគ្គលិកបញ្ជារថស្ទូចកុងតឺន័រ Rubber Tyred Gantry Crane (RTG) (ចំនួន ៣រូប)

**ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- បញ្ជារថស្ទូចកុងតឺន័រ RTG សម្រាប់ការងារលើកដាក់កុងតឺន័រ
- បញ្ចូលទិន្នន័យកុងតឺន័រក្នុងប្រព័ន្ធ Resource Director Technology (RDT)
- ទទួលខុសត្រូវលើការចូលរួមថែទាំ និងប្រើប្រាស់គ្រឿងចក្រទៅតាមបច្ចេកទេស និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។

**ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្ររងឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធ (ត្រូវបានផ្តល់អាទិភាព)
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រផ្នែករដ្ឋបាល
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបាន
- មានកាយសម្បទាល្អគ្រប់គ្រាន់
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

### ២. បុគ្គលិកបញ្ជារថស្ទូចកុងតឺន័រ Fixed Cargo Crane (FCC) (ចំនួន ៨រូប)

**ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- បញ្ជារថស្ទូចកុងតឺន័រ FCC សម្រាប់ការងារលើកដាក់កុងតឺន័រ
- បញ្ចូលទិន្នន័យកុងតឺន័រក្នុងប្រព័ន្ធ Resource Director Technology (RDT)
- ទទួលខុសត្រូវលើការចូលរួមថែទាំ និងប្រើប្រាស់គ្រឿងចក្រទៅតាមបច្ចេកទេស និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។

**ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្ររងឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធ (ត្រូវបានផ្តល់អាទិភាព)
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រផ្នែករដ្ឋបាល
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបាន
- មានកាយសម្បទាល្អគ្រប់គ្រាន់
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

៣. បុគ្គលិកបញ្ជារថស្ទូច Empty Container Stacker (ចំនួន ៨រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- បញ្ជារថស្ទូច Empty Container Stacker សម្រាប់ការងារលើកដាក់សំបកកុងតឺន័រ
- បញ្ចូលទិន្នន័យកុងតឺន័រក្នុងប្រព័ន្ធ Resource Director Technology (RDT)
- ទទួលខុសត្រូវលើការចូលរួមថែទាំ និងប្រើប្រាស់គ្រឿងចក្រទៅតាមបច្ចេកទេស និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។

ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)

- មានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្ររងឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធ (ត្រូវបានផ្តល់អាទិភាព)
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រផ្នែករដ្ឋបាល
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបាន
- មានកាយសម្បទាល្អគ្រប់គ្រាន់
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

៤. បុគ្គលិកបញ្ជារថស្ទូច ៥០តោន និង ៧០តោន (ចំនួន ២រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- បញ្ជារថស្ទូច៥០តោន និង ៧០តោន សម្រាប់ការងារលើកដាក់កុងតឺន័រ និងទំនិញ
- បញ្ចូលទិន្នន័យកុងតឺន័រក្នុងប្រព័ន្ធ Resource Director Technology (RDT)
- ទទួលខុសត្រូវលើការចូលរួមថែទាំ និងប្រើប្រាស់គ្រឿងចក្រទៅតាមបច្ចេកទេស និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។

ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)

- មានសញ្ញាបត្រចាប់ពីកម្រិតបឋមភូមិឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ឆ្នាំ (ត្រូវបានផ្តល់អាទិភាព)
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រផ្នែករដ្ឋបាល
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបាន
- មានកាយសម្បទាល្អគ្រប់គ្រាន់
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។
- មានប័ណ្ណបើកបរប្រភេទ "គ" "ឃ" ឬប្រភេទ "ង" (ប្រភេទ "ង" ត្រូវបានផ្តល់អាទិភាព)

៥. បុគ្គលិកបើកបររថយន្តដឹកកុងតឺន័រ ប្រភេទ Terminal Tractor (TT) (ចំនួន ១៧រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- បើកបររថយន្តដឹកកុងតឺន័រ TT សម្រាប់ការងារដឹកជញ្ជូនកុងតឺន័រ និងទំនិញ
- បញ្ចូលទិន្នន័យកុងតឺន័រក្នុងប្រព័ន្ធ Resource Director Technology (RDT)
- ទទួលខុសត្រូវលើការចូលរួមថែទាំ និងប្រើប្រាស់រថយន្តទៅតាមបច្ចេកទេស និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។

ខ. <u>លក្ខខណ្ឌជ្រើសរើស (Job Requirements)</u>

- មានសញ្ញាបត្រចាប់ពីកម្រិតបឋមភូមិឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ផ្នែកបើកបរយ៉ាងតិច ១ ឆ្នាំ
- មានប័ណ្ណបើកបរប្រភេទ "គ" "ឃ" ឬប្រភេទ "ង" (ប្រភេទ "ង" ត្រូវបានផ្ដល់អាទិភាព)
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសកម្រិតមធ្យម
- មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- ពុំធ្លាប់មានបទល្មើសនៃការបើកបរ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

## ៦. បុគ្គលិកផ្នែកមេកានិច (ចំនួន ៣រូប)

ក. <u>ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)</u>

- ទទួលបន្ទុកលើការងារបច្ចេកទេសមេកានិច ប្រព័ន្ធម៉ាស៊ីនត្រជាក់
- ផ្ដល់សេវាថែទាំ និងជួសជុលប្រព័ន្ធមេកានិច និងប្រព័ន្ធម៉ាស៊ីនត្រជាក់របស់គ្រឿងចក្រ រថយន្ត និងនាវាសណ្ដោង
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ អំពីស្ថានភាពប្រព័ន្ធមេកានិច និងប្រព័ន្ធម៉ាស៊ីនត្រជាក់របស់គ្រឿងចក្រ និងរថយន្ត បន្ទាប់ពីធ្វើការងារជួសជុលរួច
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ខ. <u>លក្ខខណ្ឌជ្រើសរើស (Job Requirements)</u>

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្ររងឡើងទៅ ជំនាញវិស្វកម្មមេកានិច ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារយ៉ាងតិច ១ ឆ្នាំ
- មានចំណេះដឹង និងជំនាញផ្នែកមេកានិច ជំនាញខាងត្រួតពិនិត្យប្រព័ន្ធម៉ាស៊ីន និងប្រព័ន្ធផ្សេងៗរបស់រថយន្ត/គ្រឿងចក្រតាមប្រព័ន្ធកុំព្យូទ័រ
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសកម្រិតមធ្យម
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រលើជំនាញវិស្វកម្មមេកានិច Ms. Word, Excel & Power Point
- មានអាយុចន្លោះពី ២៣ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានកាយសម្បទាល្អគ្រប់គ្រាន់
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

## ៧. បុគ្គលិកផ្នែកអេឡិចត្រូនិច (ចំនួន ២រូប)

ក. <u>ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)</u>

- ទទួលបន្ទុកលើការងារបច្ចេកទេសប្រព័ន្ធអេឡិចត្រូនិចរបស់គ្រឿងចក្រ និងរថយន្ត
- ផ្ដល់សេវាថែទាំ និងជួសជុលប្រព័ន្ធអេឡិចត្រូនិច របស់គ្រឿងចក្រ រថយន្ត និងនាវាសណ្ដោង
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ អំពីស្ថានភាពប្រព័ន្ធអេឡិចត្រូនិចរបស់គ្រឿងចក្រ និងរថយន្ត បន្ទាប់ពីធ្វើការងារជួសជុលរួច
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្ររងឡើងទៅ ជំនាញវិស្វកម្មអេឡិចត្រូនិច និងមេកានិច ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារយ៉ាងតិច ១ ឆ្នាំ
- មានចំណេះដឹង និងជំនាញផ្នែកអេឡិចត្រូនិច ជំនាញខាងត្រួតពិនិត្យប្រព័ន្ធម៉ាស៊ីន និងប្រព័ន្ធផ្សេងៗរបស់រថយន្ត/គ្រឿងចក្រតាមប្រព័ន្ធកុំព្យូទ័រ
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសកម្រិតមធ្យម
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រលើជំនាញវិស្វកម្មអេឡិចត្រូនិច Ms. Word, Excel & Power Point
- មានអាយុចន្លោះពី ២៣ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានកាយសម្បទាល្អគ្រប់គ្រាន់
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

**៨. បុគ្គលិកផ្នែកផ្សារគោន (ចំនួន ១រូប)**

**ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- ទទួលបន្ទុកលើការងារបច្ចេកទេសគោន-កាត់-ផ្សារ
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ អំពីស្ថានភាពរថយន្ត និងគ្រឿងចក្រ បន្ទាប់ពីធ្វើការងារជួសជុលគោន-កាត់-ផ្សាររួច
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ (សញ្ញាបត្របរិញ្ញាបត្រត្រូវបានផ្តល់អាទិភាព)
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ ឆ្នាំ
- មានចំណេះដឹង និងជំនាញគោន កាត់ និងផ្សារច្បាស់លាស់ ជាពិសេសការផ្សារតាមប្រព័ន្ធអេឡិចទ្រិច
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសកម្រិតមធ្យម
- មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

## V. នាយកដ្ឋានសេវាកម្មនាវាចរណ៍

**១. បុគ្គលិកផ្នែកបរិស្ថាន នៅចំណតផែកុងតឺន័រ LM១៧ (ចំនួន ២រូប)**

**ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- បោស និងលាងសំអាតនៅលើចំណតផែ ទីលាន ក្នុងបរិវេណ ក. ស. ភ.
- ចុះត្រួតពិនិត្យតំបន់សហគមន៍ ជុំវិញផែដើម្បីទប់ស្កាត់រាល់ទង្វើរបស់ប្រជាពលរដ្ឋដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន

- គ្រប់គ្រងសំណល់តាមអគាររដ្ឋបាល ក.ស.ភ.
- គ្រប់គ្រងសំណល់ រឹង រាវ ពីនាវា។

ខ. **លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ ឆ្នាំ
- មានអាយុចន្លោះពី១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

## VI. នាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក

### ១. បុគ្គលិកផ្នែកកត់ត្រាទំនិញ នៅចំណតផែទន្លេបិទ UM២ (ចំនួន ១រូប)

ក. **ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- រៀបចំចាត់ចែងទីតាំងនាវាចូលចតនៅតាមដងយោងនីមួយៗ
- កត់ត្រា និងប្រគល់ទទួលទំនិញ/កុងតឺន័រ ពីរថយន្តទៅនាវា ពីនាវាទៅរថយន្តនិងពីទីលានទៅអតិថិជន
- ផលិតប័ណ្ណបញ្ចេញទំនិញ និងធ្វើការប្រគល់ទទួលទំនិញជូនអតិថិជន
- ធ្វើរបាយការណ៍រាល់នាវាចេញចូលផែប្រចាំថ្ងៃពីសកម្មភាព Crane and Handling/Ship
- ធ្វើរបាយការណ៍បរិមាណទំនិញ/កុងតឺន័រចេញចូលប្រចាំខែ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ខ. **លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារផ្នែកកត់ត្រា ឬការងារពាក់ព័ន្ធយ៉ាងតិច ១ ឆ្នាំ
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រ Microsoft office ( Word, Excel, Power Point)
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសកម្រិតមធ្យម
- មានអាយុចន្លោះពី១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។
- មានទីលំនៅក្បែរចំណតផែទន្លេបិទ UM២ (ខេត្តត្បូងឃ្មុំ) ត្រូវបានផ្តល់អាទិភាព

### ២. បុគ្គលិកផ្នែកអនុរក្ស (ចងពួរដោះពួរនាវា) នៅចំណតផែទន្លេបិទ UM២ (ចំនួន ១រូប)

ក. **ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- ពាក់ពួរ និងដោះពួរនាវាដែលចូលចតនៅចំណតផែ
- តាមដានកម្ពស់ទឹកប្រចាំថ្ងៃ និងចងក្រងជាឯកសារ
- តាមដាន និងត្រួតពិនិត្យស្ថានភាពមធ្យោបាយបណ្តែតទឹកនានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ក. ស. ភ.
- តាមដាន និងពិនិត្យស្ថានភាពបំរែបំរួលដីច្រាំងទន្លេ ស្ថិតក្រោមការគ្រប់គ្រងរបស់ ក. ស. ភ.
- តាមដានការបំពុលបរិស្ថាន និងអនាម័យនៅចំណតផែ
- ធ្វើលិខិតស្នាមនានាពាក់ព័ន្ធការងាររដ្ឋបាល បច្ចេកទេស នាវាសណ្តោង និងកាណូតចម្លង។ល។

ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)

- មានកម្រិតវប្បធម៌ថ្នាក់បឋមភូមិឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ ឆ្នាំ
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រ Microsoft office ( Word, Excel, Power Point)
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសកម្រិតមធ្យម
- មានអាយុចន្លោះពី១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។
- មានទីលំនៅក្បែរចំណតផែទន្លេបិទ UM២ (ខេត្តត្បូងឃ្មុំ) ត្រូវបានផ្តល់អាទិភាព។

## VII. នាយកដ្ឋានផែនការ/ទីផ្សារ

### ១. អនុប្រធានការិយាល័យតម្លៃ/ទីផ្សារ (ចំនួន ១ រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- សិក្សាថ្លៃដើមប្រតិបត្តិការលើកដាក់ទំនិញក្នុង និងក្រៅចំណតផែ
- សិក្សា និងប្រៀបធៀបរវាងតម្លៃសេវារបស់ ក. ស. ភ. និងតម្លៃលើទីផ្សារ
- ធ្វើរបាយការណ៍សិក្សាថ្លៃដើមនៃប្រតិបត្តិការ
- ធ្វើរបាយការណ៍ និងករណីសិក្សាលើសំណើសុំផ្សេងៗរបស់អតិថិជន ដើម្បីស្វែងរកដំណោះ-ស្រាយ សមស្របជូនអតិថិជន
- ធ្វើការជម្រុញទីផ្សារដោយផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗ។

ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រឡើងទៅជំនាញផ្នែកទីផ្សារ នីតិសាស្ត្រ សេដ្ឋកិច្ច ពាណិជ្ជកម្ម ឬបរិញ្ញាបត្រដែលមានតម្លៃស្មើ (សញ្ញាបត្រអនុបណ្ឌិតជំនាញទីផ្សារ ត្រូវបានផ្តល់អាទិភាព)
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ៣ ឆ្នាំឡើងទៅ
- មានជំនាញទីផ្សារ សេដ្ឋកិច្ច ពាណិជ្ជកម្ម ប្រមូលនិងវិភាគព័ត៌មាន ផ្សារហ៊ុន ទំនាក់ទំនងគ្រប់គ្រង
- មានសមត្ថភាពប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ និងកម្មវិធីកុំព្យូទ័រផ្នែករដ្ឋបាលបានល្អ
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អស្ទាត់ជំនាញ (បើចេះភាសាផ្សេងបន្ថែមៈ វៀតណាម ចិន ជប៉ុន ឬកូរ៉េ ត្រូវបានផ្តល់អាទិភាព)
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

### ២. បុគ្គលិកការិយាល័យតម្លៃ/ទីផ្សារ (ចំនួន ១រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- រៀបចំផ្សព្វផ្សាយអំពីសេវាកម្មរបស់ ក. ស. ភ. តាមរយៈការរចនាគេហទំព័រ ខិត្តប័ណ្ណ ប្រតិទិន សៀវភៅ ថង់យួរ និងអាចបង្កើត និងរចនាសម្ភារផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ
- ធ្វើការផ្ទាល់ជាមួយអតិថិជន

- មានគំនិតច្នៃប្រឌិតខ្ពស់ក្នុងការបង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយពាណិជ្ជកម្ម
- មានជំនាញក្នុងការថត និងកាត់តវីដេអូ ឬភាពយន្តខ្លីៗ
- មានភាពបត់បែនក្នុងការដោះស្រាយតម្រូវការរបស់អតិថិជននិងដៃគូអាជីវកម្ម
- រក្សាទំនាក់ទំនងល្អ និងបំពេញតម្រូវការរបស់អតិថិជន
- អាចចូលរួមសិក្ខាសាលា សន្និសីទ និងព្រឹត្តិការណ៍នានាតាមការចាត់តាំង
- អាចធ្វើការក្រោមសម្ពាធ និងមានទំនួលខុសត្រូវខ្ពស់ក្នុងការងារ
- ធ្វើការងារទូទៅនៅក្នុងការិយាល័យដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ខ. <u>លក្ខខណ្ឌជ្រើសរើស (Job Requirements)</u>**

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រឡើងទៅជំនាញផ្នែក Design មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ ឆ្នាំ ក្នុងផ្នែកទីផ្សារ ផ្សព្វផ្សាយ ឬការរចនា
- មានបទពិសោធន៍ការងារលើ ការរចនាគេហទំព័រ ការរចនាជាចលនា ការរចនាខិត្តប័ណ្ណ និងការរចនាប័ណ្ណផ្សព្វផ្សាយផ្សេងៗ
- មានជំនាញផ្នែកទំនាក់ទំនង និងចរចាជាមួយអតិថិជន
- ចេះប្រើប្រាស់កុំព្យូទ័រស្ទាត់ជំនាញសម្រាប់ការងារការិយាល័យ (MS. Office, Excel,
- Photoshop, Animation programs, Corel Draw and Internet & Email)
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អ (ទាំងការសរសេរ និងនិយាយ)
- មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់
- មានគំនិតច្នៃប្រឌិតក្នុងការងារ មានជំនាញក្នុងការវិភាគ គិត និងដោះស្រាយបញ្ហា
- អាចធ្វើការស្ថិតក្រោមបរិយាកាសដែលមានសម្ពាធដើម្បីសម្រេចការងារតាមកាលកំណត់
- មានឆន្ទៈក្នុងការបំពេញការងារជាក្រុម

**៣. បុគ្គលិកផែនការគ្រឿងចក្រ (ចំនួន ១ រូប)**

**ក. <u>ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)</u>**

- ពិនិត្យផ្ទៀងផ្ទាត់គម្រោងពាក់ព័ន្ធនឹងការទិញគ្រឿងចក្រ/គ្រឿងបន្លាស់
- ពិនិត្យផ្ទៀងផ្ទាត់គម្រោងពាក់ព័ន្ធនឹងការថែទាំ-ជួសជុលគ្រឿងចក្រ
- តាមដានការប្រើប្រាស់គ្រឿងចក្រ និងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងគ្រឿងចក្រ
- ពិនិត្យផ្ទៀងផ្ទាត់ការប្រើប្រាស់ប្រេងឥន្ធនៈ និងគ្រឿងបន្លាស់របស់គ្រឿងចក្រ។

**ខ. <u>លក្ខខណ្ឌជ្រើសរើស (Job Requirements)</u>**

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រទៅលើជំនាញផ្នែក មេកានិច ឬអេឡិត្រូនិច
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ឆ្នាំ ឡើងទៅ
- អាយុមិនលើសពី ៣៥ឆ្នាំ
- មានសមត្ថភាពប្រើប្រាស់វិធីសាស្ត្រក្នុងការវិភាគទិន្នន័យនៃឥរិយាបថប្រើប្រាស់គ្រឿងចក្រ
- មានសមត្ថភាពវិភាគដោះស្រាយលើកំហូចគ្រឿងចក្រផ្នែកមេកានិច ឬអេឡិត្រូនិច
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសយ៉ាងស្ទាត់ជំនាញ

- មានសមត្ថភាពគ្រប់គ្រង ដឹកនាំ និងធ្វើការជាក្រុម
- អាចចុះការដ្ឋានជាក់ស្តែង
- មានសមត្ថភាពដោះស្រាយបញ្ហាទូទៅ ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានភាពអំណត់។

### ៤. បុគ្គលិកផែនការហេដ្ឋារចនាសម្ព័ន្ធ (ចំនួន ១ រូប)

**ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- ពិនិត្យ និងវាយតម្លៃលើសំណើសុំជាមួយអង្គភាពពាក់ព័ន្ធ
- ពិនិត្យ ផ្ទៀងផ្ទាត់ និងវិភាគលើគម្រោង ដែលបានរៀបចំឡើងដោយនាយកដ្ឋានវិស្វកម្ម
- ចុះពិនិត្យ តាមដានលើការអនុវត្តគម្រោងរបស់ក្រុមហ៊ុនទទួលការពាក់ព័ន្ធនឹងបច្ចេកទេសសាងសង់
- តាមដាន វាយតម្លៃ និងបូកសរុបនូវគម្រោងសាងសង់ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនថ្នាក់ដឹកនាំ។

**ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានបរិញ្ញាបត្រផ្នែកវិស្វកម្មសំណង់ស៊ីវិល ឬ MEP ឬផ្នែកប្រហាក់ប្រហែល ឬសញ្ញាបត្រសមមូល
- មានបទពិសោធន៍យ៉ាងតិច ២ឆ្នាំ ជាពិសេសពាក់ព័ន្ធផ្នែកវិស្វកម្មសំណង់ស៊ីវិល ឬ MEP
- មានចំណេះដឹងផ្នែកភាសាបរទេស ជាពិសេស ភាសាអង់គ្លេស អាចនិយាយ និងសរសេរបានស្ទាត់ជំនាញ
- ចេះប្រើប្រាស់កុំព្យូទ័រសម្រាប់ការងារវិស្វកម្ម (AutoCAD, Autodesk Robot, Revit Structure)
- ចេះប្រើប្រាស់កុំព្យូទ័រសម្រាប់ការងារការិយាល័យ (Ms. Word, Excel & Power Point)
- មានជំនាញក្នុងការទំនាក់ទំនង និងសម្របសម្រួលជាមួយនឹងអង្គភាពពាក់ព័ន្ធ
- មានគំនិតច្នៃប្រឌិតក្នុងការងារ និងមានសមត្ថភាពក្នុងការដោះស្រាយបញ្ហា
- មានភាពអំណត់ ស្មោះត្រង់ និងការទទួលខុសត្រូវខ្ពស់
- អាចធ្វើការស្ថិតក្រោមបរិយាកាសដែលមានសម្ពាធដើម្បីសម្រេចការងារតាមកាលកំណត់
- មានឆន្ទៈក្នុងការបំពេញការងារជាក្រុម
- មានឆន្ទៈក្នុងការសិក្សាស្វែងយល់ និងអភិវឌ្ឍសមត្ថភាពដើម្បីបំពេញការងារប្រចាំថ្ងៃ
- មានឆន្ទៈក្នុងការធ្វើការទៅតាមការបត់បែនពេលវេលា និងអាចធ្វើដំណើរផ្លូវឆ្ងាយក្នុងករណីចាំបាច់។

### ៥. បុគ្គលិកផ្នែកកិច្ចការជំនួញ/ប្រព័ន្ធ TOS (ចំនួន ១រូប)

**ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- ផលិតវិក្កយបត្រចំណូល
- ផ្ទៀងផ្ទាត់ តាមដាន និងធ្វើរបាយការណ៍លើចំណូលប្រចាំខែ
- បំពេញកិច្ចការងាររដ្ឋបាលទូទៅក្នុងការិយាល័យ

ខ. <u>លក្ខខណ្ឌជ្រើសរើស</u> (Job Requirements)

- មានបរិញ្ញាបត្រផ្នែកគណនេយ្យ Accounting ឬផ្នែកប្រហាក់ប្រហែល ឬសញ្ញាបត្រសមមូល
- មានបទពិសោធន៍យ៉ាងតិច ២ឆ្នាំ ជាពិសេសពាក់ព័ន្ធផ្នែកចំណូល
- មានចំណេះដឹងផ្នែកភាសាបរទេស ជាពិសេស ភាសាអង់គ្លេស អាចនិយាយ និងសរសេរបានស្ទាត់ជំនាញ
- ចេះប្រើប្រាស់កុំព្យូទ័រស្ទាត់ជំនាញសម្រាប់ការងារការិយាល័យ (Ms. Word, Excel, Power Point &Internet)
- មានជំនាញក្នុងការទំនាក់ទំនង និងសម្របសម្រួលជាមួយនឹងអង្គភាពពាក់ព័ន្ធ
- មានគំនិតច្នៃប្រឌិតក្នុងការងារ និងមានសមត្ថភាពក្នុងការដោះស្រាយបញ្ហា
- មានភាពអំណត់ ស្មោះត្រង់ និងការទទួលខុសត្រូវខ្ពស់
- អាចធ្វើការស្ថិតក្រោមបរិយាកាសដែលមានសម្ពាធដើម្បីសម្រេចការងារតាមកាលកំណត់
- មានឆន្ទៈក្នុងការបំពេញការងារជាក្រុម
- មានឆន្ទៈក្នុងការសិក្សាស្វែងយល់ និងអភិវឌ្ឍសមត្ថភាពដើម្បីបំពេញការងារប្រចាំថ្ងៃ
- មានឆន្ទៈក្នុងការធ្វើការទៅតាមការបត់បែនពេលវេលា និងអាចធ្វើដំណើរផ្លូវឆ្ងាយក្នុងករណីចាំបាច់។

## ៦. បុគ្គលិកផ្នែកភស្តុភារកម្ម (ចំនួន ១រូប)

ក. <u>ភារកិច្ចទទួលខុសត្រូវ</u> (Job Responsibilities)

- សិក្សា/វិភាគលើថ្លៃដើម និងស្នើសុំកំណត់តម្លៃសម្រាប់សេវាកម្មដឹកជញ្ជូន ក៏ដូចជាសេវាកម្មជាកញ្ចប់សម្រាប់ទំនិញនាំចេញ/នាំចូល
- ជួបពិភាក្សាជាមួយអតិថិជនដើម្បីផ្សព្វផ្សាយ និងទាក់ទាញអតិថិជនមកប្រើប្រាស់សេវាកម្មភស្តុភារកម្ម
- ទំនាក់ទំនង និងសម្របសម្រួលរវាងក្រុមការងារភស្តុភារកម្ម និងអតិថិជន ដើម្បីផ្តល់សេវាកម្មឱ្យបានឆាប់រហ័ស និងអាចបំពេញតាមតម្រូវការរបស់អតិថិជន
- ប្រមូលឯកសារពាក់ព័ន្ធ រួចធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់លើព័ត៌មានចាំបាច់មួយចំនួន ដើម្បីសម្រួលដល់ការងារចេញវិក្កយបត្រគិតថ្លៃសេវាកម្មទៅអតិថិជន
- ពិនិត្យ និងរៀបចំជារបាយការណ៍ចំណេញ/ខាតប្រចាំខែ សម្រាប់សេវាកម្មដឹកជញ្ជូនក្រៅចំណតផែ។

ខ. <u>លក្ខខណ្ឌជ្រើសរើស</u> (Job Requirements)

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ជំនាញផ្នែកភស្តុភារកម្ម គណនេយ្យ ហិរញ្ញវត្ថុ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ ឆ្នាំ
- មានសមត្ថភាពលើការសិក្សា/វិភាគលើថ្លៃដើម និងការកំណត់តម្លៃសម្រាប់សេវាកម្មដឹកជញ្ជូន
- មានសមត្ថភាពប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ និងគណនេយ្យកុំព្យូទ័របានល្អ
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អ
- មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

៧. បុគ្គលិកការិយាល័យស្រាវជ្រាវ/អភិវឌ្ឍន៍ថ្មី (ចំនួន ១រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- រៀបចំកម្រងសំណួរ និងរបៀបប្រមូលព័ត៌មាន និងទិន្នន័យផ្សេងៗ
- វិភាគទិន្នន័យ និងសរសេរគម្រោង
- សិក្សា និងរៀបចំតម្លៃគម្រោង
- សិក្សា និងវាយតម្លៃគម្រោង។

ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)

- មានបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកប្រហាក់ប្រហែល ឬសញ្ញាបត្រសមមូល
- មានបទពិសោធន៍ក្នុងការសរសេរគម្រោងយ៉ាងតិច ២ឆ្នាំ
- មានអាយុមិនលើសពី ៣៥ឆ្នាំ
- មានចំណេះដឹងផ្នែកភាសាបរទេស ជាពិសេស ភាសាអង់គ្លេស អាចនិយាយ និងសរសេរបានស្ទាត់ជំនាញ
- ចេះប្រើប្រាស់កុំព្យូទ័រសម្រាប់ការងារការិយាល័យ (Ms. Word, Excel & Power Point) និង Internet/E-mail
- មានជំនាញក្នុងការទំនាក់ទំនង និងសម្របសម្រួលជាមួយនឹងអង្គភាពពាក់ព័ន្ធ
- មានគំនិតច្នៃប្រឌិតក្នុងការងារ និងមានសមត្ថភាពក្នុងការដោះស្រាយបញ្ហា
- មានភាពអំណត់ ស្មោះត្រង់ និងការទទួលខុសត្រូវខ្ពស់
- អាចធ្វើការស្ថិតក្រោមបរិយាកាសដែលមានសម្ពាធដើម្បីសម្រេចការងារតាមកាលកំណត់
- មានឆន្ទៈក្នុងការបំពេញការងារជាក្រុម
- មានឆន្ទៈក្នុងការសិក្សាស្វែងយល់ និងអភិវឌ្ឍសមត្ថភាពដើម្បីបំពេញការងារប្រចាំថ្ងៃ
- មានឆន្ទៈក្នុងការធ្វើការទៅតាមការបត់បែនពេលវេលា
  និងអាចធ្វើដំណើរផ្លូវឆ្ងាយក្នុងករណី ចាំបាច់។

## VIII. នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧

១. បុគ្គលិកផ្នែកវិក្កយបត្រ នៅចំណតផែកុងតឺន័រ LM១៧ (ចំនួន ១រូប)

ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)

- ផលិតវិក្កយបត្រ និងគណនាថ្លៃសេវាកម្មនានារបស់ក. ស. ភ. រួមមាន LoLo និង Gate Fee, LoLo Scan, LoLo ICD, ថ្លៃស្តុក, Stuffing/Unstuffing, សេវាកម្មទូកុងតឺន័រត្រជាក់...
- ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ (បញ្ជីតម្លៃ, LoLo Scan, LoLo ICD Report, etc)
- ទំនាក់ទំនងជាមួយអតិថិជនលើការងារលើកដាក់ទំនិញ និងសម្របសម្រួលការងារផ្សេងៗ
- រៀបចំឯកសារសម្រាប់សវនកម្ម
- អនុវត្តការងារផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ជំនាញផ្នែកគណនេយ្យ ហិរញ្ញវត្ថុ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ ឆ្នាំ

- មានសមត្ថភាពប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ និងគណនេយ្យកុំព្យូទ័របានល្អ
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អ
- អាចបំពេញការងារនៅការិយាល័យ និងទីតាំងផ្សេងៗតាមការចាត់តាំង
- មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់។

បើបេក្ខជនមានចំណាប់អារម្មណ៍ សូមចូលរួមដាក់ពាក្យប្រលងប្រជែងចូលបម្រើការងារនៅក. ស. ភ. ដោយមានភ្ជាប់ជាមួយនូវប្រវត្តិរូបសង្ខេប (CV) និង Cover Letter ដោយមានបិទរូបថតថ្មីទំហំ ៤ x ៦ លិខិតបញ្ជាក់សញ្ញាបត្រ ឬការសិក្សា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ លិខិតបញ្ជាក់កំណើត និងប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ (ឯកសារថតចម្លង) មកដាក់នៅទីស្នាក់ការកណ្តាលកំពង់ផែស្វយ័តភ្នំពេញ (ចំណតផែ TS៣) ដែលមានទីតាំងស្ថិតនៅ អគារលេខ ៦៤៩ បន្ទប់១១០ តីរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈអ៊ីម៉ែល ឬតេឡេក្រាមដូចខាងក្រោម៖

អ៊ីម៉ែល: rimsokrath@gmail.com / chitphanetedu@gmail.com
តេឡេក្រាម: Rim Sokrăth (លេខទូរស័ព្ទ: ០១០ ៤៤៤ ៥៣៨)
Phanet Chit (លេខទូរស័ព្ទ: ០១០ ៤៤៤ ២៣៩)
លេខទូរស័ព្ទទំនាក់ទំនង: ០១០ ៤៤៤ ៥៣៨/០១០ ៤៤៤ ២៣៩/០៩៣ ៤៤៤ ៥១៧

**កាលបរិច្ឆេទឈប់ទទួលពាក្យ**: ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២

**បញ្ជាក់**: - បេក្ខជនដែលជាប់ក្នុងបញ្ជីសម្រាំងជ្រើសរើស (Short-listed candidates) នឹងត្រូវបានជូនដំណឹងស្តីពីការចូលរួមប្រលង ក្នុងគេហទំព័ររបស់ក. ស. ភ. (www.ppap.com.kh)

- រាល់ឯកសារដែលបានដាក់ពាក្យរួចហើយរបស់បេក្ខជន មិនអាចដកវិញបានទេ។

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានអគ្គនាយក**

**ហ៊ី-បាវី**